CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៨ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងនឹងផ្តល់វគ្គស្តាប់ពីសហគមន៍បន្ថែមដែលជាផ្នែកមួយនៃ "ក្របខ័ណ្ឌសម្រាប់ការផ្សះផ្សានៅឡុងប៊ិច"

ទីក្រុងឡុងប៊ិច,រដ្ឋកាលីហ្វ័រញ៉ា - ដោយសារតែតម្រូវការខ្ពស់និងក្នុងការខិតខំឱ្យសមាជិកសាធារណៈបន្ថែមផ្តល់គំនិតផ្លាស់ប្តូរដែលប្រកបដោយអត្ថន័យចំពោះគ្រប់ទិដ្ឋភាពនៃភាពអយុត្តិធម៌និងភាពមិនស្មើភាពគ្នានៅឡុងប៊ិចទីក្រុងកំពុងតែបន្ថែមវគ្គស្តាប់ពីសហគមន៍កាន់តែច្រើននិងពង្រីកសមត្ថភាពចូលរួមក្នុងវគ្គស្តាប់នីមួយៗក៏ដូចជារៀបចំសាលប្រជុំសាឡាក្រុងចំនួនបីសម្រាប់ការចូលរួមជាសាធារណៈ។ ព្រឹត្តិការណ៍ទាំងនេះគឺជាផ្នែកមួយនៃ "ក្របខ័ណ្ឌសម្រាប់ការផ្សះផ្សានៅឡុងប៊ិច" ដែលបានអនុម័តជាឯកច្ឆន្ទដោយក្រុមប្រឹក្សាក្រុងដើម្បីទទួលស្គាល់នូវអត្ថិភាពនិងបង្កើតផែនការដើម្បីដោះស្រាយការប្រកាន់ពូជសាសន៍ដែលមានជាយូរមកហើយនៅក្នុងក្រុងនិងនៅសហរដ្ឋអាមេរិក។

លោកស្រី Teresa Chandler អនុប្រធានក្រុងបានថ្លែងថា "យើងទទួលស្គាល់ថាមនុស្សជាច្រើនចង់បញ្ចេញមតិយោបល់ក្នុងដំណើរការដ៏សំខាន់និងហួសកាលកំណត់នេះ។ យើងបានបន្ថែមវគ្គទាំងនេះដើម្បីស្តាប់ពីប្រជាជនកាន់តែច្រើននិងធ្វើការផ្លាស់ប្តូរចំពោះរចនាសម្ព័ន្ធដើម្បីធ្វើឱ្យមានតុល្យភាពរវាងការចូលរួមកាន់តែទូលំទូលាយនឹងការធានានូវការពិភាក្សាដែលមានសណ្តាប់ធ្នាប់និងអត្ថន័យ។

មានវិធីបីយ៉ាងដែលសមាជិកសហគមន៍អាចចូលរួមនិងបញ្ចេញគំនិតយោបល់របស់ពួកគាត់។ ប្រជាជនអាចចូលរួមក្នុងសាលប្រជុំសាឡាក្រុងឬផ្តល់យោបល់ជាលាយលក្ខណ៍អក្សរដោយការបំពេញការស្ទង់

មតិខ្លីតាមអ៊ិនធរណេតឬដោយផ្ញើរយោបល់ឬសំណួររបស់ពួកគាត់ទៅកាន់ EquityLB@longbeach.gov ឬចូលរួមវគ្គស្តាប់ពីសហគមន៍ដែលនឹងមានការសម្របសម្រួល។

**ខាងក្រោមនេះរួមមានព័ត៌មាននិងការចុះឈ្មោះសម្រាប់សាលប្រជុំសាឡាក្រុងដែលបានបន្ថែមថ្មីៗនិងវគ្គស្តាប់ពីសហគមន៍បន្ថែមផងដែរ៖**

- សាលប្រជុំសាលាក្រុងសហគមន៍៖ បែបវេទិកាបើកចំហរ

  June 30, 5:30 p.m.

  July 9, 5:30 p.m.

  July 12, 4 p.m.

- សមធម៌ពូជសាសន៍នៅទូទាំងប្រព័ន្ធទាំងអស់ (រួមមានសុខភាពសេដ្ឋកិច្ចការអប់រំ។ ល។)

  June 18, 5:30 p.m. - 7 p.m.

  June 30, 5:30 p.m. - 7 p.m.

- សាលប្រជុំសាលាក្រុងសហគមន៍៖ ការងារប៉ូលីសនិងសុវត្ថិភាពសាធារណៈ

  June 22, 5:30 p.m. - 7:30 p.m.

- វិសាលគមនៃសុវត្ថិភាពរបស់សហគមន៍

  June 24, 5:30 p.m. - 7 p.m.

  July 2, 10 a.m. - 11:30 a.m.

- សមធម៌ផ្នែកសុខភាព

  June 25, 5:30 p.m. - 7 p.m.

  June 28, 6 p.m. - 7:30 p.m.

- សមធម៌ពូជសាសន៍ដែលទាក់ទងនឹងលំនៅដ្ឋាននិងភាពគ្មានផ្ទះសម្បែង

  June 26, 10 a.m. - 11:30 a.m.

[July 1, 5:30 p.m. - 7 p.m.]

- **សមធម៌ផ្នែកសេដ្ឋកិច្ច**
  [June 29, 10 a.m. - 11:30 a.m.]
  [July 2, 5:30 p.m. - 7 p.m.]

- **សមធម៌ក្នុងការអប់រំនិងសេវាកម្មយុវជន**
  [June 29, 5:30 p.m. - 7 p.m.]
  [July 3, 10 a.m. - 11:30 a.m.]

ដើម្បីអនុលោមតាមបទបញ្ជាសុខភាពបច្ចុប្បន្ននិងវិធានការណ៍រក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នារបស់ទីក្រុងវគ្គស្តាប់នឹងត្រូវធ្វើតាមអ៊ិនធរណេតនាពេលនេះ។ ព័ត៌មានលំអិតបន្ថែមនិងព័ត៌មានអំពីការចុះឈ្មោះគឺមាននៅលើគេហទំព័ររបស់ការិយាល័យសមធម៌នៃទីក្រុងឡុងប៊ិច។

ព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌសម្រាប់ការផ្សះផ្សាគឺអាចរកបាននៅលើគេហទំព័រសមធម៌និងនៅក្នុងសេចក្តីប្រកាសព័ត៌មាននេះ។

**ក្របខ័ណ្ឌនៃការផ្សះផ្សាឡុងប៊ិចទាក់ទងនឹងជំហានសំខាន់ៗចំនួនបួន៖**

- **ការទទួលស្គាល់**នូវអត្ថិភាពនិងផលប៉ះពាល់ជាយូរមកហើយនៃការប្រកាន់ពូជសាសន៍នៅឡុងប៊ិចនិងនៅក្នុងប្រទេស។
- **ស្តាប់**ពីរឿងរ៉ាវដែលបានកើតឡើងនិងបទពិសោធន៍នៃភាពអយុត្តិធម៌ខាងពូជសាសន៍វិសមធម៌ឬគ្រោះថ្នាក់ដែលបានកើតឡើងចំពោះសមាជិកសហគមន៍។
- **កោះហៅប្រជុំ**រវាងភាគីពាក់ព័ន្ធដើម្បីវាយតម្លៃលើយោបល់នានាដែលទទួលបានពីការស្តាប់ហើយរៀបចំគោលនយោបាយផ្នែកថវិកាធម្មនុញ្ញនិងគំនិតកំណែទម្រង់កម្មវិធី។
- **ចាត់វិធានការ**រហ័សដែលបង្ហាញនូវអនុសាសន៍ភ្លាមៗក្នុងរយៈពេលខ្លីមធ្យមនិងវែងសម្រាប់ឲ្យក្រុមប្រឹក្សាក្រុងធ្វើការពិចារណា។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដែលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបានការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេងហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #